ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី
«ទទួលបានប្រាក់រង្វាន់ ២០,០០០ រៀល ជាមួយកម្មវិធី អ៊ីអនវ៉ាឡេត»
បញ្ញត្តិ និងលក្ខខណ្ឌ

<u>និយមន័យ៖</u>

- **កម្មវិធីប្រូម៉ូសិន៖** សំដៅលើកម្មវិធី **«ទទួលបានប្រាក់រង្វាន់ ២០,០០០ រៀល ជាមួយកម្មវិធី អ៊ីអនវ៉ាឡេត»**ដែលរៀបចំដោយ **អ៊ីអន អេសភីប៊ី** ស្របតាមបញ្ញត្តិ និងលក្ខខណ្ឌដែលបានកំណត់នាពេលនេះ។
- **អ៊ីអន អេសភីប៊ី៖** សំដៅទៅលើ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី។
- **«អតិថិជនដែលមានសិទ្ធិ» ៖** សំដៅលើអតិថិជនដែលមិនធ្លាប់បានចុះឈ្មោះប្រើប្រាស់កម្មវិធី អ៊ីអនវ៉ាឡេត ពីមុន និងបំពេញតាមលក្ខខណ្ឌទាំងអស់ដែលបានកំណត់នៅក្នុងបញ្ញត្តិ និងលក្ខខណ្ឌទាំងនេះ។ (មិនរាប់បញ្ចូលបុគ្គលិករបស់ អ៊ីអន អេសភីប៊ី) ។
- **ទីតាំងដែលមានសិទ្ធិ៖** សំដៅលើសាខារបស់ អ៊ីអន អេសភីប៊ី ដែលបានកំណត់ដូចខាងក្រោម និងមានទីតាំងស្ថិតនៅក្នុងផ្សារទំនើបអ៊ីអន៖
  - សាខាអ៊ីអន ម៉ល ភ្នំពេញ
  - សាខាអ៊ីអន ម៉ល សែនសុខ
  - សាខាអ៊ីអន ម៉ល មានជ័យ

<u>រយៈពេលប្រូម៉ូសិន៖</u>

កម្មវិធីប្រូម៉ូសិននេះចាប់ផ្តើមពីថ្ងៃទី **២០ ខែវិច្ឆិកា ឆ្នាំ២០២៦ ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៦ («រយៈពេលប្រូម៉ូសិន»)** រួមទាំងថ្ងៃបុណ្យជាតិផងដែរ ឬអាចត្រូវបានបន្ត កែប្រែ ផ្អាក ឬបញ្ចប់ តាមការសម្រេចចិត្តតែមួយគត់ និងដាច់ខាតរបស់ **អ៊ីអន អេសភីប៊ី** ដោយមិនបាច់ជូនដំណឹងជាមុនឡើយ។

<u>ព័ត៌មានលម្អិតអំពីការផ្តល់ជូន៖</u>

អតិថិជនដែលមានសិទ្ធិ ដែលបានចុះឈ្មោះកម្មវិធី អ៊ីអនវ៉ាឡេត ដោយជោគជ័យ និងបានបំពេញការផ្ទៀងផ្ទាត់អត្តសញ្ញាណពេញលេញ (Full KYC) នៅទីតាំងដែលមានសិទ្ធិ ក្នុងអំឡុងពេលប្រូម៉ូសិន នឹងទទួលបាន ប្រាក់រង្វាន់ ២០,០០០ រៀល ស្របតាមបញ្ញត្តិ និងលក្ខខណ្ឌនៃកម្មវិធីប្រូម៉ូសិននេះ។

<u>លក្ខខណ្ឌប្រូម៉ូសិន៖</u>

- កម្មវិធីប្រូម៉ូសិននេះផ្តល់ជូនសម្រាប់តែអតិថិជនថ្មី ដែលមិនធ្លាប់បានចុះឈ្មោះប្រើប្រាស់កម្មវិធី អ៊ីអនវ៉ាឡេត ពីមុនប៉ុណ្ណោះ (មិនរាប់បញ្ចូលបុគ្គលិករបស់ធនាគារឯកទេស អ៊ីអន។
- អតិថិជនដែលមានសិទ្ធិត្រូវចុះឈ្មោះកម្មវិធី អ៊ីអនវ៉ាឡេត ដោយជោគជ័យ និងបំពេញការផ្ទៀងផ្ទាត់អត្តសញ្ញាណពេញលេញ (Full KYC) នៅទីតាំងដែលមានសិទ្ធិណាមួយ ក្នុងអំឡុងពេលប្រូម៉ូសិន។
- អតិថិជនដែលមានសិទ្ធិម្នាក់ៗ ដែលបានបំពេញការចុះឈ្មោះកម្មវិធី អ៊ីអនវ៉ាឡេត និងការផ្ទៀងផ្ទាត់អត្តសញ្ញាណពេញលេញ (Full KYC) ដោយជោគជ័យ នឹងទទួលបាន ប្រាក់រង្វាន់ ២០,០០០ រៀល ដែលនឹងត្រូវបញ្ចូលដោយផ្ទាល់ទៅក្នុងគណនីអ៊ីអនវ៉ាឡេត របស់អតិថិជន។
- ប្រាក់រង្វាន់ នឹងត្រូវបញ្ចូលទៅក្នុងគណនី អ៊ីអនវ៉ាឡេត របស់អតិថិជនដែលមានសិទ្ធិ ស្របតាមកាលវិភាគខាងក្រោម ដោយផ្អែកលើការផ្ទៀងផ្ទាត់ជោគជ័យលើសិទ្ធិរបស់អតិថិជន និងការបំពេញនីតិវិធីអនុម័ត និងដំណើរការដែលតម្រូវ៖
  - អតិថិជនដែលបានបំពេញការផ្ទៀងផ្ទាត់អត្តសញ្ញាណពេញលេញ (Full KYC) ដោយជោគជ័យ នឹងទទួលបានទឹកប្រាក់ត្រឡប់ចូលគណនីនៅថ្ងៃបន្ទាប់។ ក្នុងករណីដែលការចុះឈ្មោះ ឬការផ្ទៀងផ្ទាត់ត្រូវបានធ្វើឡើងនៅថ្ងៃចុងសប្តាហ៍ ឬថ្ងៃឈប់សម្រាកសាធារណៈ ទឹកប្រាក់ត្រឡប់ចូលគណនីនឹងត្រូវបញ្ចូលនៅថ្ងៃធ្វើការបន្ទាប់។
- អតិថិជនដែលមានសិទ្ធិម្នាក់ៗអាចទទួលបានទឹកប្រាក់ត្រឡប់វិញតែ ១ ដងប៉ុណ្ណោះ ក្នុងអំឡុងពេលប្រូម៉ូសិន ដោយមិនគិតពីទីតាំងដែលមានសិទ្ធិ ដែលបានបំពេញការចុះឈ្មោះ និងការផ្ទៀងផ្ទាត់អត្តសញ្ញាណ។
- ប្រាក់រង្វាន់ ត្រូវបានផ្តល់ជូនតាមគោលការណ៍ មកមុន ទទួលបានមុន (First-Come, First-Served Basis) និងអាស្រ័យលើថវិកាដែលបានកំណត់សម្រាប់កម្មវិធីប្រូម៉ូសិន។ អ៊ីអន អេសភីប៊ី រក្សាសិទ្ធិក្នុងការបញ្ឈប់ការផ្តល់ ប្រាក់រង្វាន់ នៅពេលថវិកាកម្មវិធីប្រូម៉ូសិនត្រូវបានប្រើប្រាស់អស់ ទោះបីជារយៈពេលប្រូម៉ូសិនមិនទាន់បញ្ចប់ក៏ដោយ។
- បុគ្គលិករបស់ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី និងក្រុមហ៊ុនក្នុងសម្ព័ន្ធ អ៊ីអន មិនមានសិទ្ធិចូលរួមកម្មវិធីប្រូម៉ូសិននេះឡើយ។
- អតិថិជនត្រូវផ្តល់ព័ត៌មានឱ្យបានត្រឹមត្រូវ និងពេញលេញ ព្រមទាំងគោរពតាមតម្រូវការចុះឈ្មោះ និងបំពេញការផ្ទៀងផ្ទាត់អត្តសញ្ញាណពេញលេញ របស់អ៊ីអន អេសភីប៊ី ។ អ៊ីអន អេសភីប៊ី រក្សាសិទ្ធិក្នុងការបដិសេធការចុះឈ្មោះ ឬសិទ្ធិទទួលបាន ប្រាក់រង្វាន់ ប្រសិនបើរកឃើញការចុះឈ្មោះស្ទួន ព័ត៌មានមិនត្រឹមត្រូវ សកម្មភាពក្លែងបន្លំ ឬការរំលោភបំពានលក្ខខណ្ឌណាមួយនៃកម្មវិធីប្រូម៉ូសិន។

- អ៊ីអន អេសភីប៊ី រក្សាសិទ្ធិក្នុងការកែប្រែ ផ្អាក ឬបញ្ចប់កម្មវិធីប្រូម៉ូសិននេះ និង/ឬ កែប្រែលក្ខខណ្ឌទាំងនេះ ដោយមិនចាំបាច់ជូនដំណឹងជាមុន។

ការដកសិទ្ធិ:

អ៊ីអន អេសភីប៊ី រក្សាសិទ្ធិផ្តាច់មុខក្នុងការដកសិទ្ធិចូលរួមរបស់អតិថិជនដែលមានសិទ្ធិណាមួយ ដោយមិនចាំបាច់ជូនដំណឹងជាមុនក្នុងករណី:

(ក) អតិថិជនត្រូវទាញយក និងចុះឈ្មោះ អ៊ីអនវ៉ាឡេត ដោយជោគជ័យ អំឡុងពេលប្រូម៉ូសិន យោងតាម AEON Wallet Terms and Conditions។

(ខ) អតិថិជនដែលមានសិទ្ធិបានផ្តល់ព័ត៌មានមិនពិត មិនត្រឹមត្រូវ ឬបំភាន់ ក្នុងអំឡុងពេលចុះឈ្មោះ ឬដំណើរការផ្ទៀងផ្ទាត់អត្តសញ្ញាណពេញលេញ (Full KYC)។ ឬ

(គ) អតិថិជនដែលមានសិទ្ធិត្រូវបានរកឃើញថាបានប្រព្រឹត្តសកម្មភាពក្លែងបន្លំ ការចុះឈ្មោះស្តួន ឬការប្រើប្រាស់កម្មវិធីប្រូម៉ូសិនខុសគោលបំណង។ ឬ

(ឃ) អតិថិជនដែលមានសិទ្ធិបានរំលោភបំពានលក្ខខណ្ឌណាមួយដែលមានចែងនៅក្នុងបញ្ជាក្តី និងលក្ខខណ្ឌទាំងនេះ។

ការទទួលខុសត្រូវ:

អ៊ីអន អេសភីប៊ី មិនទទួលខុសត្រូវចំពោះការបាត់បង់ ការខូចខាត ឬការទាមទារណាមួយដែលកើតឡើងចំពោះអតិថិជនដែលមានសិទ្ធិ ដោយសារឬពាក់ព័ន្ធនឹងការចូលរួមក្នុង**កម្មវិធីប្រូម៉ូសិននេះ** រួមទាំង ប៉ុន្តែមិនកំណត់ត្រឹមការខូចខាតដោយផ្ទាល់ ដោយប្រយោល ដោយចៃដន្យ ដោយបន្តបន្ទាប់ ដោយពិសេស ឬការខូចខាតក្នុងលក្ខណៈពិន័យ ការបាត់បង់ប្រាក់ចំណូល ប្រាក់ចំណេញ ឬកេរ្តិ៍ឈ្មោះ ឬការអនុវត្តសិទ្ធិរបស់ **អ៊ីអន អេសភីប៊ី** ស្របតាមបញ្ជាក្តី និងលក្ខខណ្ឌទាំងនេះ លើកលែងតែករណីដែលច្បាប់ និងបទប្បញ្ញត្តិជាធរមានកំណត់ផ្សេងពីនេះ។

ខចែងផ្សេងទៀត:

(ក) រាល់ការសម្រេចចិត្តរបស់ អ៊ីអន អេសភីប៊ី ពាក់ព័ន្ធនឹងកម្មវិធីប្រូម៉ូសិននេះ គឺជាការសម្រេចចិត្តចុងក្រោយ និងមានអានុភាពចងក្រង។ មិនមានការទទួលយកការឆ្លើយឆ្លង ឬវិវាទណាមួយពាក់ព័ន្ធនឹងការសម្រេចចិត្តទាំងនោះឡើយ។ បញ្ហាក្តី និងលក្ខខណ្ឌទាំងនេះ ត្រូវស្ថិតក្រោម និងបកស្រាយស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

(ខ) តាមរយៈការចូលរួមក្នុងកម្មវិធីប្រូម៉ូសិននេះ អតិថិជនដែលមានសិទ្ធិទាំងអស់ត្រូវបានចាត់ទុកថាបានអាន យល់ និងយល់ព្រមលើបញ្ជាក្តី និងលក្ខខណ្ឌទាំងនេះ។ អ៊ីអន អេសភីប៊ី រក្សាសិទ្ធិក្នុងការផ្អាក បញ្ចប់ ឬលុបចោលកម្មវិធីប្រូម៉ូសិននេះនៅពេលណាមួយ ដោយមិនចាំបាច់បញ្ជាក់មូលហេតុ និងជូនដំណឹងជាមុន។ ការជូនដំណឹង ឬព័ត៌មានថ្មីៗអំពីកម្មវិធីប្រូម៉ូសិននេះ អាចត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័ររបស់ អ៊ីអន អេសភីប៊ី៖ **www.aeon.com.kh**

គ) សម្រាប់ការណែនាំ និង/ឬមតិយោបល់ពាក់ព័ន្ធនឹងប្រូម៉ូសិននេះ សូមទាក់ទងមកកាន់លេខទូរស័ព្ទទាន់ហេតុការណ៍របស់ អ៊ីអន អេសភីប៊ី តាមរយៈទូរស័ព្ទទៅលេខ ០២៣/០៧០/០៧៨ ៩៨៨ ៥៥៥។